# គណៈមេធាវីនៃទីក្រុងអាំស្ទែដាំ

សម្គាល់
អង្គជំនុំជម្រះសាលាដំបូង
អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក)
ផ្ញើជូន៖ លោក K. Roberts មន្ត្រីច្បាប់ជាន់ខ្ពស់
ប្រអប់សំបុត្រលេខ ៧១
រាជធានីភ្នំពេញ
ប្រទេសកម្ពុជា

មេធាវី V.L. Koppe
តាមរយៈអ៊ីមែល៖ koppe@un.org

ឯកសារទទួល
DOCUMENT RECEIVED/DOCUMENT REÇU
ថ្ងៃ ខែ ឆ្នាំ (Date of receipt/date de reception): 25 / 04 / 2016
ម៉ោង (Time/Heure) : 15:30
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé
du dossier: SANN RADA

**ទីក្រុងអាំស្ទែដាំ ថ្ងៃទី១៥ ខែមីនា ឆ្នាំ២០១៦**

**PvRA/kb**

**ឯកសារយោងរបស់យើងខ្ញុំ៖ ៥០-១៥-០៨៦២**

**ឯកសារយោងរបស់លោក៖ លោក នួន ជា - សំណុំរឿង ០០២/០២**

ជូនចំពោះលោក Roberts

យោងតាមលិខិតរបស់អង្គជំនុំជម្រះវិសាមញ្ញកម្ពុជាក្នុងតុលាការកម្ពុជាចុះថ្ងៃទី១៦ ខែកុម្ភៈ ខ្ញុំបានទទួលបណ្តឹងដែលអង្គជំនុំជម្រះសាលាដំបូងបានដាក់ប្តឹង V. Koppe មេធាវីនៃគណៈមេធាវីនៃទីក្រុងអាំស្ទែដាំដែលតំណាងជនសង្ស័យមួយរូបដែលកំពុងទទួលការជំនុំជម្រះក្តីនៅចំពោះមុខអង្គជំនុំជម្រះ។ សេចក្តីដកស្រង់ចេញមកពីប្រតិចារឹកនៃសវនាការពាក់ព័ន្ធរួមមាននៅក្នុងបណ្តឹង និងឧបសម្ព័ន្ធនៃបណ្តឹងនោះ។ ខ្ញុំបានដាក់បញ្ចូលបណ្តឹងនេះជាភាសាហូឡង់ និងឧបសម្ព័ន្ធសម្រាប់មេធាវី Koppe ផងដែរ។

Original Dutch: 01224090-01224091
Note: This Khmer translation is based on the English version which was translated from the original Dutch text.

ដូចបានលើកឡើងនាពេលមុនរួចហើយ ខ្ញុំនឹងពិនិត្យមើលបណ្ដឹងនេះស្របតាមគោលការណ៍ណែនាំថ្នាក់ជាតិសម្រាប់ពិចារណាលើបណ្ដឹង របស់ប្រធានគណៈមេធាវី។ ខ្ញុំបានបញ្ជូនច្បាប់ថតចម្លងនៃគោលការណ៍ណែនាំ និងសេចក្ដីសង្ខេបយ៉ាងខ្លីជាភាសាអង់គ្លេសជូនអង្គជំនុំជម្រះ ហើយខ្ញុំក៏បានផ្ដល់ច្បាប់ថតចម្លងនៃឯកសារទាំងនេះជាភាសាហូឡង់ ជូនមេធាវី Koppe ផងដែរ។ គោលការណ៍ណែនាំថ្នាក់ជាតិទាំងនេះអាចរកបានក្នុងទម្រង់អេឡិចត្រូនិកតាមរយៈអាសយដ្ឋានតភ្ជាប់លើគេហទំព័រនៃគណៈមេធាវីនៃទីក្រុងអាំស្ទែដាំដូចខាងក្រោមនេះ៖ https://www.advocatenorde-amsterdam.nl/9824/menupagina-klachten.html។

ខ្ញុំសូមស្នើសុំឱ្យមេធាវី Koppe បង្ហាញជំហររបស់គាត់ទាក់ទងនឹងបណ្ដឹងនេះ។ គាត់គប្បីបង្ហាញជំហរតាមរយៈការពិភាក្សាលើអង្គហេតុ ដូចបានលើកឡើងនៅក្នុងបណ្ដឹង ព្រមទាំងសេចក្ដីសន្និដ្ឋានរបស់គាត់ផង។

យោងតាមបទដ្ឋានហូឡង់ដ៏ លក្ខខណ្ឌវាយតម្លៃលើវិជ្ជាជីវៈមេធាវីមានចែងនៅក្នុងមាត្រា ៤៦ នៃលក្ខន្តិកៈមេធាវី។ មាត្រានេះចែងថា មេធាវីត្រូវស្ថិតក្រោមកិច្ចដំណើរការនីតិវិធីវិន័យចំពោះអំពើ ឬ ការខកខានណាមួយដែលផ្ទុយនឹងកាតព្វកិច្ចប្រកបវិជ្ជាជីវៈដោយយកចិត្តទុកដាក់ ពោលគឺ មេធាវីត្រូវអនុវត្តចំពោះបុគ្គលទាំងឡាយដែលខ្លួនកំពុងការពារ ឬត្រូវការពារផលប្រយោជន៍ឱ្យ ចំពោះការរំលោភបទប្បញ្ញត្តិនៃលក្ខន្តិកៈច្បាប់ស្ដីពីការទប់ស្កាត់ការលាងលុយ និងហិរញ្ញប្បទាននៃអំពើភេរវកម្ម បទប្បញ្ញត្តិស្ដីពីគណៈមេធាវីនៃប្រទេសហូឡង់ និងចំពោះសកម្មភាព និងការខកខានដែលធ្វើឱ្យប៉ះពាល់ដល់កេរ្តិ៍ឈ្មោះមេធាវី ។

នេះជាបទដ្ឋានទូលំទូលាយមួយដែលត្រូវបកស្រាយដោយមេធាវី។ គោលការណ៍ចម្បងនៃវិជ្ជាជីវៈច្បាប់ដូចមានចែងនៅក្នុងមាត្រា ១០ (ក) នៃលក្ខន្តិកៈមេធាវី មានសារៈសំខាន់ណាស់សម្រាប់ការបកស្រាយបែបនេះ។ គោលការណ៍ចម្បងទាំងនេះចែងថា មេធាវីត្រូវអនុវត្តដោយឯករាជ្យ ទាក់ទិននឹងកូនក្ដី តតីយជន និងរឿងក្ដីដែលខ្លួនការពារក្ដីក្នុងនាមជាមេធាវី។ មេធាវីត្រូវការពារផលប្រយោជន៍ស្របច្បាប់របស់កូនក្ដីខ្លួន។ មេធាវីត្រូវប្រកបដោយវិជ្ជាជីវៈ និងមានចំណេះដឹង និងបំណិនគ្រប់គ្រាន់។ មេធាវីត្រូវស្មោះត្រង់ និងជៀសវាងសកម្មភាព ឬ ការខកខានណាមួយដែលធ្វើឱ្យប៉ះពាល់ដល់កេរ្តិ៍ឈ្មោះមេធាវី ហើយចំណុចចុងក្រោយ មេធាវីត្រូវជាទីប្រឹក្សាសម្ងាត់ដោយត្រូវគោរពគោលការណ៍រក្សាការសម្ងាត់ដូចមានចែងនៅក្នុងលក្ខន្តិកៈ និងច្បាប់។

គោលការណ៍ចម្បងទាំងនេះពុំអនុវត្តចំពោះមេធាវីនៅក្នុងគណៈមេធាវីនៃប្រទេសហូឡង់ តែប៉ុណ្ណោះទេ។ គោលការណ៍នេះមានការគាំទ្រធំធេងនៅក្នុងបរិបទនៃទ្វីបអឺរ៉ុបនៅតាមបណ្ដាស្ថាប័នវិជ្ជាជីវៈមេធាវីក្នុងបណ្ដាប្រទេសនៃទ្វីបអឺរ៉ុបផងដែរ ហើយ ជាទូទៅ គោលការណ៍ទាំងនេះ មានចែងនៅក្នុងក្រមវិជ្ជាជីវៈសម្រាប់មេធាវីនៅទ្វីបអឺរ៉ុបផងដែរ។

E378/1/1

ខ្ញុំរង់ចាំការឆ្លើយតបពីមេធាវី Koppe។ ក្រោយពេលទទួលបានចម្លើយតបរួច ខ្ញុំនឹងបញ្ជូនចម្លើយតបនោះជូនអង្គជំនុំជម្រះដើម្បីឲ្យអង្គជំនុំជម្រះមានឱកាសឆ្លើយតបទៅនឹងជំហររបស់មេធាវី Koppe។

សូមលោកទទួលនូវការគោរពរាប់អានដោយស្មោះត្រង់អំពីខ្ញុំ។

[ហត្ថលេខា]

P.N. van Regteren Altena